# កំណាយនៅឡខ្នារពោធិ

ឡខ្នារពោធិជាក្រុមឡមួយផ្សេងទៀត ស្ថិតនៅក្នុងភូមិបុស្ស ឃុំខ្នារពោធិ ស្រុកសូត្រនិគម ខេត្តសៀមរាប។ វាមានចម្ងាយប្រហែល២០គីឡូម៉ែត្រ ឆ្ពោះត្រង់ពីខាងកើតប្រាសាទអង្គរវត្ត ឬប្រហែ១០គីឡូម៉ែត្រពីស្ថានីយ៍ឡសរសៃ (រូបលេខ១)។ ស្ថានីយ៍ឡខ្នារពោធិនេះត្រូវបានប្រជាជននៅក្នុងតំបន់ផ្តល់ពត៌មានដល់ក្រុមស្រាវជ្រាវបុរាណវិទ្យារបស់អាជ្ញាធរអប្សារាក្នុងឆ្នាំ១៩៩៥។[១] ក្រោយមក ក្នុងឆ្នាំ២០០៤ កញ្ញា ឯម សុជាតា បានធ្វើការសិក្សាស្រាវជ្រាវជាលើដំបូងអំពីផលិតផលកុលាលភាជន៍ និងបច្ចេកទេសនានាដែលគេបានអនុវត្តនៅស្ថានីយ៍ឡនេះ សម្រាប់ធ្វើជាសារណាបញ្ចប់ការសិក្សាបរិញ្ញាប័ត្របុរាណវិទ្យា។[២] តាមរយៈការសិក្សានេះ គាត់បានធ្វើផែនទី និងបែងចែកក្រុមឡជា៣ក្រុមគឺ៖ ក្រុម(ក) នៅលើទំនប់ខាងលិចរបស់បារាយណ៍ដ៏ធំមួយ (មានចំនួន៥ឬ៦ទួលឡ) ក្រុម (ខ) គឺបណ្តាលទួលឡនៅដាច់ៗ តែផ្នែកខាងនីរតីនៃជើងទំនប់ (មានចំនួនប្រហែល៦ឬ៧ទួលឡ) និងក្រុម(គ)ស្ថិតនៅលើទំនប់ខាងត្បូង មានចំនួនមិនច្បាស់។

**តើហេតុអ្វីបានជាគេជ្រើសរើសយកតំបន់នេះសម្រាប់ផលិតកុលាលភាជន៍?**

ជាការពិតណាស់ ទីកន្លែងមួយដែលគេជ្រើសរើសសម្រាប់រស់នៅ និងធ្វើសិប្បកម្មភាជន៍នោះ គឺវាមានចំនុចពិសេសមួយចំនួន ដូចជា៖

ក. ជាកន្លែងដែលសំបូរនិងផ្តល់នូវរូបធាតុដើម គឺដីឥដ្ឋ ពោលគឺនៅជុំវិញតំបន់នេះសំបូរទៅដោយដីឥដ្ឋពណ៌ក្រហម ពិសេសនៅក្នុងផ្ទៃបាតបារាណ៍។ យើងពុំឃើញមានដីឥដ្ឋពណ៌ស និងពណ៌លឿងដូចនៅស្ថានីយ៍ឡសរសៃទេ។

ខ. តំបន់នេះស្ថិតនៅទិសអាគ្នេយ៍នៃជើងភ្នំគូលេន ដែលផ្តល់នូវប្រភពទឹកទាំងខែប្រាំង និងខែវស្សា។ ដូចនេះហើយគេបានស្ថាបនាបារាយណ៍ដ៏ធំមួយមានទំនប់ខាងត្បូង និងខាងលិច ដើម្បីរក្សាទឹកទុកប្រើប្រាស់។

គ. ជាប្រភពនៃថាមពល គឺព្រៃសម្រាប់ប្រើជាអុសក្នុងការដុតកុលាលភាជន៍។

ឃ. ជាតំបន់នៅជិតអង្គរ ងាយស្រួលដឹកជញ្ជូនផលិតផលទៅកាន់ទីក្រុង

[១] អ៊ា ដារិទ្ធ, (២០០០:៣៨)

[២] ឯម សុជាតា, (២០០៤)

អត្ថបទដោយ៖ សុខ កែវសុវណ្ណារ៉ា

AMS

## គោលបំណងនៃការជ្រើសរើសធ្វើកំណាយ

តាមការពិនិត្យជាស្តែង ស្ថានីយ៍ឡខ្នារពោធិនេះរងការបំផ្លាញស្ទើទាំងស្រុង ដោយការអភិវឌ្ឍន៍ផ្លូវថ្មីក្នុងភូមិ។ ក្រុម "ក" ដែលស្ថិតនៅលើខ្នងទំនប់ខាងលិច និងក្រុម "គ" នៅលើខ្នងទំនប់ខាងត្បូងត្រូវបានគេឈូសឆាយចោលដល់បាតឡទាំងស្រុង (រូបលេខ២) ពុំមានទួលឡមួយណាដែលអាចឱ្យធ្វើការស្រាវជ្រាវ និងធ្វើកំណាយបានទេ។ ចំណែកក្រុមឡ "ខ" វិញក៏ត្រូវបានម្ចាស់ដីគាស់បំផ្លាញដើម្បីធ្វើចំការដែរ។ នៅសល់តែទួលឡ "២១" (រូបលេខ៣) និង"២៤"ទេដែលនៅសល់រូបរាងទាំងស្រុង និងអាចធ្វើកំណាយស្រាវជ្រាវបាន។

## ស្ថាប័នចូលរួម និងរយៈពេលកំណាយ

កំណាយលើកនេះ មានការចូលរួមដោយស្ថាប័នថ្មី គឺសាកលវិទ្យាល័យអូតានីអូសាកា នៃប្រទេសជប៉ុន។ ដូចនេះមានការចូលរួមដោយស្ថាប័ន៣ គឺវិទ្យាស្ថានស្រាវជ្រាវជាតិណារ៉ា សាកលវិទ្យាល័យអូតានីអូសាកា និងអាជ្ញាធរជាតិអប្សរា។

ក្រុមស្រាវជ្រាវបានជ្រើសរើសទួលឡលេខ ២១ ដើម្បីសិក្សា និងធ្វើកំណាយ។

កំណាយនេះចាប់ផ្តើមក្នុងឆ្នាំ២០០៦ដល់២០០៨ និងមានការធ្វើកំណាយលើទួលឡចំនួន៤ដង ដើម្បីពិនិត្យលម្អិតលើរចនាសម្ព័ន្ធរបស់ឡលេខ ២១នេះ។

## ការធ្វើកំណាយ

កំណាយបានអនុវត្តចាប់ពីឆ្នាំ២០០៦រហូតដល់ឆ្នាំ២០០៨ ដោយមានការជីកកកាយលើទួលឡលេខ ២១យ៉ាងលម្អិត។ ទួលឡនេះមានទំហំបណ្តោយប្រហែល៨ម៉ែត្រ ទទឹងប្រហែល៦ម៉ែត្រ និងកម្ពស់ប្រហែល៣ម៉ែត្រ។ ផ្នែកខាងលើ មានសល់កម្រាល់ឡ។

- កំណាយលើកទី១ ចាប់ពីថ្ងៃទី១១ ដល់ទី១៥ ខែធ្នូ ឆ្នាំ២០០៦ ជាការចាប់ផ្តើមបើកការដ្ឋាន សម្អាតទួលឡ និងរៀបចំកំណាយ។ ក្នុងបេសកកម្មនេះ យើងបានជីករកឃើញរូបរាងឡដែលនៅសល់ រួមមានជញ្ជាំង និងកម្រាល។
- កំណាយទី២ ក្នុងខែមីនា ការបើករណ្តៅពង្រីកបន្ថែម និងពុះពាក់កណ្តាលឡ
- កំណាយលើកទី៣ ចាប់ពីថ្ងៃ១៣ដល់១៩ ខែវិច្ឆិកា ២០០៧ ជាការធ្វើកំណាយបន្តដើម្បីពិនិត្យឱ្យបានច្បាស់អំពីរចនាសម្ព័ន្ធឡ។

អត្ថបទដោយ៖ សុខ កែវសុវណ្ណារ៉ា

- កំណាយលើកទី៤ ចាប់ពីថ្ងៃ១០ ដល់១១ ខែមិថុនា ជាកំណាយចុងក្រោយ ដោយបង្កើយការជីក និងបន្តកិច្ចការវ៉ាស់ទំហំឡ និងរចនាសម្ព័ន្ធផ្សេងៗ។

កំណាយដំបូង គេបានបើករណ្ដៅតូចៗនៅជុំវិញទួលឡ ដើម្បីស្វែងរករូបរាងដើមទាំងស្រុងរបស់វា (រូបលេខ៤)។ បន្ទាប់មក គេពង្រីកបន្ថែមទៅតាមអ្វីដែលគេរកឃើញៗ។ នៅបេសកកម្មទី៣ គេបានបើកយ៉ាងទូលាយនៅទួលឡនេះ ដោយបានជួបប្រទះនូវរចនាសម្ព័ន្ធទាំងមូលរបស់ឡ (រូបលេខ៥)។

### លទ្ធផលកំណាយ

តាមរយៈកំណាយ គេអាចដឹងថាទំហំឡនេះមានរាងជាពងក្រពើទ្រវែង ដូចគ្នាទៅនិងឡ ក១១ នៅស្ថានីយកូមិសរសី បណ្ដោយប្រហែល៦ម៉ែត្រ ទទឹងជញ្ជាំងប្រវែង២.២ម៉ែត្រ ទៅ២.៦ម៉ែត្រ និងកំពស់ពីលើដល់បន្ទប់ដុតអុសប្រហែល៣ម៉ែត្រ(រូបលេខ៦)។ ដំបូលទាំងមូលបានបាក់អស់ នៅសល់ត្រឹមគល់ជញ្ជាំង។ ពីលើដល់ល្បាក់បន្ទប់ដុតអស់មានគល់សសរចំនួនប្រាំ ដែលសសរនីមួយៗមានស្នាមប្រហោងឈើនៅចំកណ្ដាល។ នៅលើសសរ២ក្បែរបន្ទប់ភ្លើងត្រូវបានគេលាបស្រទាប់លោងពណ៌បៃតងពាសពេញ រួមទាំងកម្រាលខ្លះផង។ នៅក្នុងបន្ទប់ដុតអស់មានសសរចំនួន៥ដើម (រូបលេខ៧) ជាសសរទ្រដំបូលដែលគេបានរួញចូលក្នុងបន្ទាប់ពីគេលែងប្រើប្រាស់តទៅទៀត។ នេះជាលើកទី១ហើយដែលយើងរកឃើញសសរទ្រដំបូលឡ ព្រោះការធ្វើកំណាយនៅឡតានី និងឡសរសី មិនដែលមានសល់សសរនៅក្នុង ឬជុំវិញឡទេ។ ចំពោះបន្ទប់ដុតអុសមានរន្ធបញ្ចូលអុស២ និងរន្ធខ្យល់១ ហើយត្រូវបានគេពាសដោយស្រទាប់លោង។ រន្ធបញ្ចូលខាងឆ្វេងត្រូវគេបិទចោលនៅក្នុងការប្រើប្រាស់ចុងក្រោយ (រូបលេខ៨)។

### អំពីផលិតផលកុលាលភាជន៍

តាមការសង្កេត និងលទ្ធផលកំណាយ ឃើញថា ឡខ្នារពោធិមានផលិតភាគច្រើនជាភាជន៍ធំៗដូចជា ក្រឡ ឧទិន ក្អម ផើងពាង និងក្បឿងជាដើម។ ចំនុចនេះវាខុសគ្នានៅឡតានី និងឡសរសី[1] ភាគច្រើនផលិតភាជន៍តូចៗ និងធំភាគតិច (រូបលេខ៩ និងលេខ១០)។

---

[1] សុខ កែវ សុវណ្ណារ៉ា (២០០៣)

អត្ថបទដោយ៖ សុខ កែវសុវណ្ណារ៉ា

សរុបមក ឃើញថារូបរាងឡខ២១នេះគឺស្មើដូចគ្នាទៅនិងឡតានី និងសរសី ខុសគ្នាត្រង់ទំហំបន្តិចបន្តួចប៉ុណ្ណោះ។ ចំណែកផលិតផលភាជន៍គឺមានភាពខុសគ្នាភាគច្រើន។ ចំពោះកាលបរិច្ឆេទស្ថានីយ៍ គេនៅមិនទាន់ទទួលបានលទ្ធផលវិភាគទេ។



រូបលេខ២១៖ ទីតាំងឡខ្នារពោធិ



រូបលេខ២២៖ តួឡដែលគេឈូសចោល



រូបលេខ២៣៖ ទួលឡ ខ២១



រូបលេខ២៤៖ ការបើកគំណាយដំបូង



រូបលេខ២៥៖ សកម្មភាពកំណាយ



រូបលេខ២៦៖ រូបរាងទួលឡទាំងមូល

អត្ថបទដោយៈ សុខ កែវសុវណ្ណារ៉ា



រូបលេខ៧៖ សសរទ្រទ្រង់ដំបូល



រូបលេខ៨៖ រន្ធបញ្ចូលអុសខាងឆ្វេង



រូបលេខ៩៖ បំណែកភាជន៍ឡខ្នារពោធិ



រូបលេខ១០៖ បំណែកភាជន៍ឡសរសី

## ឯកសារយោង


សុខ កែវ សុវណ្ណារ៉ា.

២០០៣. *កុលាលភាជន៍ឡសរសី*, សារណាបរិញ្ញាប័ត្របុរាណវិទ្យា, ភ្នំពេញ។

អ៊ា ដារិទ្ធ.

២០០០:៣៨ *សង្ខេបទិន្នន័យថ្មីៗនៃកុលាលភាជន៍ខ្មែរ*, ក្នុង ឧទ័យ, លេខ១, សៀមរាប។

ឯម សុជាតា.

២០០៤, *ស្ថានីយ៍ឡខ្នារពោធិ*, សារណាបញ្ចប់បរិញ្ញាប័ត្របុរាណវិទ្យា, ភ្នំពេញ។


អត្ថបទដោយ៖ សុខ កែវសុវណ្ណារ៉ា